**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ប្រ.ក/លេខ ១០.១៦៧/០៨ គ.ជ.ប.អគ្គ.ពស

ភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨

# គ.ជ.ប បានស្នើរដ្ឋសភាកាត់ប្រាក់បំណាច់ ប្រចាំខែរបស់ឯកឧត្តម សម រង្ស៊ី

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) បានចេញលិខិតមួយ លេខ ១១១២/០៨ គ.ជ.ប ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៨ ជូនសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ដើម្បីចាត់វិធានការកាត់ប្រាក់បំណាច់ពីឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី និងជាសមាជិករដ្ឋសភាដោយសារតែគាត់មិនបានបង់ប្រាក់ពិន័យមក គ.ជ.ប តាមកាលកំណត់ ចំពោះករណីដែលគាត់ប្រព្រឹត្តល្មើសនឹងច្បាប់បោះឆ្នោត ហើយត្រូវបានដាក់ពិន័យដោយក្រុមប្រឹក្សាជំនុំជំរះ គ.ជ.ប កាលពីថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ កន្លងមកចំនួនដប់លាន ( ១០.០០០.០០០) រៀល ។

លិខិតរបស់ គ.ជ.ប ដែលផ្ញើជូនសម្តេចប្រធានរដ្ឋសភា មានខ្លឹមសារថា ដើម្បីធានានូវនីត្យានុកូលភាព ( ភាពស្របច្បាប់) របស់ច្បាប់ គ.ជ.ប ស្នើសុំសម្តេចអគ្គមហាពញាចក្រីប្រធានរដ្ឋសភា ចាត់វិធានការកាត់ប្រាក់បំណាច់ប្រចាំខែរបស់ឯកឧត្តម សម រង្ស៊ី ដែលជាសមាជិករដ្ឋសភាបង់ចូលថវិកាជាតិតាមរយៈ គ.ជ.ប ។

សូមបញ្ជាក់ថា នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឯកឧត្តម សម រង្ស៊ី ត្រូវបានក្រុមប្រឹក្សាជំនុំជំរះ នៃ គ.ជ.ប សម្រេចផ្តន្ទាទោសពិន័យជាប្រាក់ចំនួនដប់លាន ( ១០.០០០.០០០) រៀល ពីបទជេរប្រមាថថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ក្នុងពេលដែលគាត់ដឹកនាំក្បួនឃោសនាបោះឆ្នោតនៅតាមបណ្តាខេត្តមួយចំនួនក្នុងភូមិភាគពាយ័ព្យ(?) នៃប្រទេស ។ បន្ទាប់មកតំណាងគណបក្សសម រង្ស៊ី មិនទទួលយកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជំរះ គ.ជ.ប បានបន្តប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ហើយក្រុមប្រឹក្សាជំនុំជំរះ នៃក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចតម្កល់សេចក្តីសម្រេចរបស់ គ.ជ.ប ទុកជាបានការពេញទាំងមូល ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា និងមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

កាលពីថ្ងៃទី ១៨ ខែ កញ្ញា គ.ជ.ប បានសម្រេចចេញសេចក្តីបង្គាប់ឱ្យឯកឧត្តម សម រង្ស៊ី ចូលខ្លួនមកបង់ប្រាក់ពិន័យនៅទីស្តីការ គ.ជ.ប ( នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម) ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីបង្គាប់ឱ្យបង់ប្រាក់នេះ ក្នុងករណីមិនបានមកបង់ប្រាក់តាមពេលវេលាកំណត់ទេ គ.ជ.ប នឹងចាត់វិធានការតាមផ្លូវច្បាប់ ។ ប៉ុន្តែរហូតមកដល់ពេលនេះ ឯកឧត្តម សម រង្ស៊ី ពុំបានចូលខ្លួនមកបង់ប្រាក់តាមកាលណាត់នោះនៅឡើយ ។/.